ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៣៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

***មាត្រា ១:***

បង្កើតគណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ ដែលមាន សមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម ចម ប្រសិទ្ធ | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២-ឯកឧត្តម សុក ស៊ីផាន់ណា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣-ឯកឧត្តម ព្រុំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤-ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៥-ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៦-ឯកឧត្តម ចន្ទ តុងអ៊ីវ | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ៧-ឯកឧត្តម នី យ៉ាវ | រដ្ឋលេខាធិការក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨-ឯកឧត្តម អ៊ិត ប្រាំង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩-ឯកឧត្តម ស្វ វិចនំរ | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០-ឯកឧត្តម ចី ចំនួនផល | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១-ឯកឧត្តម សារ៉ាក់ ខាន់ | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១២-លោកជំទាវ ស៊ិន សារះភឿន | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៣-ឯកឧត្តម លាភ វណ្ណដេន | អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៤-លោក ជា វណ្ណដេត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥-ឯកឧត្តម អភិបាលខេត្ត រតនៈគិរី | | សមាជិក |
| ១៦-ឯកឧត្តម អភិបាលខេត្ត ស្ទឹងត្រែង | | សមាជិក |
| ១៧-ឯកឧត្តម អភិបាលខេត្ត ព្រះវិហារ | | សមាជិក |
| ១៨-លោក ឆេង សារឿន | អគ្គនាយករងបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម | ជាលេខាធិការ |

*មាត្រា* ២:

គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ មានភារកិច្ចៈ

១- សិក្សាឯកសារ និងរៀបចំអនុសាសន៍ស្តីពីលទ្ធភាព និងគំរូផែនការអភិវឌ្ឍន៍រួមគ្នា នៃតំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

២- ធ្វើជាដៃគូចរចាជាមួយភាគី វៀតណាម-ឡាវ-ថៃ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

៣- រៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀង ក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

៤- រៀបចំផែនការសកម្មភាពសំរាប់អនុវត្តនូវកិច្ចព្រមព្រៀងក្នុងក្របខ័ណ្ឌនេះ

៥- រៀបចំកម្មវិធី និងគំរោងវិនិយោគអាទិភាព ដើម្បីជំរុញការអនុវត្តនូវកិច្ចព្រមព្រៀងក្របខ័ណ្ឌ នៃតំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ម្យាវ-ថៃ

៦- សំរបសំរួលការងារជាមួយបណ្តាក្រសួង-ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ

៧- ទំនាក់ទំនង និងគៀងគរធនធានហិរញ្ញវត្ថុ ពីអ្នកផ្តល់ជំនួយ និងផ្នែកឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស សំរាប់ធ្វើការសិក្សាស្រាវជ្រាវ និងអនុវត្តនូវកម្មវិធី និងគំរោងអាទិភាព

៨- ពង្រឹងការឯកភាពគ្នា ក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌប្រទេសអាស៊ាន

៩- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

១០-គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ ត្រូវរាយការណ៍អំពីលទ្ធផលការងារខាងលើ ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសំរេច ។

## មាត្រា ៣ :

គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ អាចប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម រាល់លិខិតផ្លូវការរបស់ខ្លួន និងមានថវិកាសំរាប់ការងាររបស់ខ្លួន ដែលធ្វើជាមួយ និងគណនីរបស់ក្រសួងពាណិជ្ជកម្ម ។

សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

## មាត្រា ៤:

គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ នេះ មានលេខាធិការដ្ឋាន ដែលមានទីស្នាក់ការនៅទីស្តីការក្រសួងពាណិជ្ជកម្ម ។ លេខាធិការដ្ឋាននេះត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួន តាមការចាំបាច់ ។ មន្ត្រីជំនួយការ ក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ឬជាមន្ត្រីក្របខ័ណ្ឌ ដែលអាចស្នើសុំ ពីក្រសួង ស្ថាប័ននានា របស់រាជរដ្ឋាភិបាល ។

**មាត្រា ៥ :**

លេខាធិការដ្ឋានមាន ភារកិច្ចដូចតទៅ:

១- សំរបសំរួលដំណើរប្រព្រឹត្តទៅរបស់គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ មានជាអាទិ៍ ការរៀបចំផែនការការងារ ការរៀបចំកិច្ចប្រជុំ និងរបៀបវារៈនៃអង្គប្រជុំ របស់គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ

២- សំរបសំរួល និងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ដែលជាសមាជិកគណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ និងជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត

៣- ជាដៃគូចរចា កិច្ចបច្ចេកទេសជាមួយភាគី វៀតណាម ឡាវ និង ថៃ

៤- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រធានគណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍ តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ ។

**មាត្រា ៦.**

ចំពោះមុខគណៈកម្មការនេះ ត្រូវបង្កើតក្រុមការងារបួនក្រុមគឺ:

- ក្រុមការងារពាណិជ្ជកម្ម
- ក្រុមការងារសាធារណការ និងដឹកជញ្ជូន
- ក្រុមការងារទេសចរណ៍
- និងក្រុមការងារឧស្សាហកម្មរ៉ែ-ថាមពល ។

គណៈកម្មការសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ អាចបង្កើតក្រុមការងារ បន្ថែមទៀតបើយល់ឃើញថាចាំបាច់ ។

**មាត្រា ៧.**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

*មាត្រា ៨.*

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង សាមីខ្លួនដែលមានចែងក្នុងមាត្រា១ និងអភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែ មេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ចម ប្រសិទ្ធ**

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៨

-ឯកសារ-កាលប្បវត្តិ